**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

សេចក្តីព្រាង

# ច្បាប់

## ស្តីពី

## សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

***********

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលដៅ

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងល័ក្ខខ័ណ្ឌនៃការចុះបញ្ជី សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងការចុះអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-** គោលបំណង

ច្បាប់នេះមានគោលបំណង :

- ផ្តល់សិទ្ធិ ដល់ប្រជាពលរដ្ឋខ្មែរ ក្នុងការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីរួមគ្នាការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ
- ផ្តល់ឱកាសឱ្យអង្គការមិនមែនរដ្ឋាភិបាលបរទេស ចូលរួមជាមួយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រម្ពុជា ក្នុងការអនុវត្តគម្រោងជំនួយនានា
- ផ្តល់ឱកាសឱ្យមានការចូលរួមសហប្រតិបត្តិការ រវាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ជាមួយរាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សង្គមកម្ពុជា។

**មាត្រា ៣.-** វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជី និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈ នៅព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់នេះ។

**មាត្រា ៤.-** និយមន័យ

នៅក្នុងច្បាប់នេះ :

-សមាគម សំដៅដល់ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីគិតគូពីផលប្រយោជន៍សមាជិក ឬនិងផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។

-អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សំដៅដល់ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធា-រណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។

-អង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅដល់ក្រុមរូបវន្តបុគ្គលជាជនជាតិបរទេស នៅបរទេស ដែលបានបង្កើតឡើងក្រោមច្បាប់បរទេស ហើយបានមកធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។

-ពាក្យថាអង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

**មាត្រា ៥.-** ការបង្កើតនីតិបុគ្គល

នៅក្នុងច្បាប់នេះ :

-សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ជានីតិបុគ្គលមិនយកចំណេញ។

-អង្គការមិនមែនរដ្ឋាភិបាលបរទេស ជានីតិបុគ្គលបរទេស។

នីតិបុគ្គលត្រូវគោរពតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៦.-** បញ្ញត្តិហាមឃាត់

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី ឬចុះអនុស្សរណៈ មិនត្រូវទទួលបានផលប្រយោជន៍ពីច្បាប់នេះ និងមិនអាចធ្វើសកម្មភាពក្នុងនាមជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលធ្វើសកម្មភាពក្នុងរយៈពេលតិចជាងមួយ(០១)ឆ្នាំ ពុំចាំបាច់ចុះអនុស្សរណៈទេ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីគម្រោងជំនួយ ពេលវេលា និងទីកន្លែងអនុវត្ត ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី ២
## ការចុះបញ្ជី សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា ៧.-** សមត្ថកិច្ចចុះបញ្ជី

ការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

ក្រសួងមហាផ្ទៃ អាចធ្វើប្រតិភូកម្មអំណាចនៃការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទៅឱ្យស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៨.-** លក្ខខណ្ឌនៃការចុះបញ្ជីសមាគម

ដើម្បីចុះបញ្ជីសមាគមបាន ត្រូវមានសមាជិកស្ថាបនិក ដែលមានសញ្ជាតិខ្មែរចំនួនពីដប់មួយ(១១)នាក់ឡើងទៅ។

សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំសមាគម យ៉ាងតិចប្រាំ(០៥)នាក់ សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌស្នើសុំចុះបញ្ជី។

**មាត្រា ៩.-** លក្ខខណ្ឌនៃការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ដើម្បីចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបាន ត្រូវមានអ្នកផ្តួចផ្តើមដែលមានសញ្ជាតិខ្មែរយ៉ាងតិចបី(០៣)នាក់ឡើងទៅ។

សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើសប្រធានមួយ(០១)រូប សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌស្នើសុំចុះបញ្ជី។

**មាត្រា ១០.-** លក្ខន្តិកៈរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ថ្នាក់ដឹកនាំរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវរៀបចំលក្ខន្តិកៈរបស់ខ្លួន។

លក្ខន្តិកៈរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវគោរពតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

លក្ខន្តិកៈរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវមានចែងចំណុចសំខាន់ៗដូចខាងក្រោម :

- ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញាសម្គាល់
- គោលដៅ និងគោលបំណង
- វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងប្រធាន និងថ្នាក់ដឹកនាំ

-សិទ្ធិ និងភារកិច្ចរបស់សមាជិក ឬបុគ្គលិក

-រចនាសម្ព័ន្ធ អាណត្តិ តួនាទី ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការដឹកនាំនានា

-អង្គការដឹកនាំនានា រួមមានសន្និបាត ក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការនាយក ឬគណៈកម្មាធិការប្រតិបត្តិ ឬអង្គការសមមូល

-វិធាននៃការប្រជុំសាមញ្ញ ឬវិសាមញ្ញនៃអង្គការដឹកនាំនានា

-ប្រភពធនធាន និងទ្រព្យសម្បត្តិ

-វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

-វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

-វិធាននៃការរំលាយ និងវិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ។

**មាត្រា ១១.-** ការប្រើឈ្មោះ និងសញ្ញាសម្គាល់របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវកំណត់អំពីឈ្មោះ និងសញ្ញាសម្គាល់ ដូចខាងក្រោម :

-ឈ្មោះ ត្រូវមានអត្ថន័យជាខ្មែរ

-សញ្ញាសម្គាល់ មិនត្រូវចម្លងតាមរូបសញ្ញាស្ថាប័នជាតិ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិផ្សេងៗ។

-ឈ្មោះជាអក្សរពេញ និងសញ្ញាសម្គាល់របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលនឹងបង្កើតក្រោយ មិនត្រូវយកឈ្មោះជាអក្សរពេញ ឬនិងសញ្ញាសម្គាល់របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីមុនរួចហើយ។

**មាត្រា ១២.-** ទីស្នាក់ការ

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវមានទីស្នាក់ការកណ្តាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៣.-** ការកំណត់ថ្លៃអាករចុះបញ្ជី

ថ្លៃអាករចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៤.-** សំណុំលិខិតសុំចុះបញ្ជីសមាគម

ប្រធានសមាគមត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ឬនៅស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់មកជាមួយនូវ សំណុំលិខិតដូចខាងក្រោម :

- ពាក្យសុំចុះបញ្ជីដោយប្រធានសមាគម ពីរ(០២)ច្បាប់
- តារាងបញ្ជីឈ្មោះស្ថាបនិកចំនួនចាប់ពីដប់មួយ(១១)នាក់ ឡើងទៅដោយមានបញ្ជាក់អំពីអាយុ ភេទ សញ្ជាតិ អាសយដ្ឋានអចិន្ត្រៃយ៍។ សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំសមាគម យ៉ាងតិចចំនួនប្រាំ(០៥)នាក់ សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌស្នើសុំចុះបញ្ជី
- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគម ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់មួយ(០១)ច្បាប់
- លក្ខន្តិកៈ ចុះហត្ថលេខាដោយប្រធាន និងថ្នាក់ដឹកនាំសមាគមទាំងអស់ពីរ(០២)ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំសមាគម យ៉ាងតិចចំនួនប្រាំ(០៥)នាក់ ក្នុងម្នាក់ពីរ(០២)ច្បាប់ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤ គុណនឹង ៦
- បង្កាន់ដៃថ្លៃអាករចុះបញ្ជីសមាគមមួយ(០១)ច្បាប់ ។

**មាត្រា ១៥.-** សំណុំលិខិតសុំចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ឬនៅស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម :

- ពាក្យសុំចុះបញ្ជីដោយប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ(០២)ច្បាប់
- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់មួយ(០១)ច្បាប់
- លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ពីរ(០២)ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក យ៉ាងតិចបី(០៣)នាក់ ក្នុងម្នាក់ពីរ(០២)ច្បាប់ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤ គុណនឹង ៦
- បង្កាន់ដៃថ្លៃអាករចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ(០១)ច្បាប់។

ប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវធានាថានឹងប្រគល់លិខិតប្រកាសគណនីធនាគាររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានផ្ញើនៅធនាគារណាមួយទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជាមួយ(០១)ច្បាប់ រយៈពេលយ៉ាងយូរសាមសិប(៣០)ថ្ងៃនៃថ្ងៃ

ធ្វើការបន្ទាប់ពីថ្ងៃបានទទួលលិខិតសម្រេចចុះបញ្ជី។ ក្នុងករណី មិនបានផ្តល់តាមកាលកំណត់ខាងលើនេះ ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលុបឈ្មោះអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ចេញពីបញ្ជីវិញ។

**មាត្រា ១៦.-** បង្កាន់ដៃទទួលពាក្យសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រគល់បង្កាន់ដៃទទួលពាក្យសុំចុះបញ្ជីមួយ(០១)ច្បាប់ជូនសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានបំពេញសំណុំលិខិតគ្រប់គ្រាន់តាមការកំណត់ដូចមានចែងក្នុងមាត្រា១៤ ឬមាត្រា១៥ នៃច្បាប់នេះ។

**មាត្រា ១៧.-** ការពិនិត្យសំណុំលិខិត ការកែតម្រូវ និងការឆ្លើយតប

ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពិនិត្យសំណុំលិខិត និងនីត្យានុកូលភាពនៃលក្ខន្តិកៈរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជី ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃនៃថ្ងៃធ្វើការ។

ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសាមីសមាគម ឬសាមីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិមិនព្រមទទួលចុះបញ្ជីដោយឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីពិនិត្យឃើញថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានកែតម្រូវខ្លឹមសារសមស្រប ឬចំណុចខ្វះខាតរួចហើយ ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ។

ក្នុងករណី ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចមិនព្រមទទួលចុះបញ្ជីសាមីសមាគម ឬសាមីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការ។

**មាត្រា ១៨.-** ពេលវេលាកំណើតនៃនីតិបុគ្គល

សមាគមនឹងក្លាយជានីតិបុគ្គលមិនយកចំណេញចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិបានចុះបញ្ជីរួច។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិបានចុះបញ្ជីរួចជាស្ថាពរ។

## ជំពូកទី ៣

## ការចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា ១៩.-** និយមន័យ

សម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល សំដៅដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានរៀបចំចងក្រងគ្នាជាសម្បាច់ក្នុងគោលបំណងរួមណាមួយ ដើម្បីធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ដោយមិនយកចំណេញមកចែកគ្នា។

**មាត្រា ២០.-** សមត្ថកិច្ចចុះបញ្ជី

ការចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ២១.-** លក្ខខណ្ឌនៃការចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ដើម្បីចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបាន ត្រូវមានសមាជិកស្ថាបនិកដែលជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកស្របច្បាប់ យ៉ាងហោចណាស់ពីរ(០២)ឡើងទៅ។

សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើសប្រធានសម្ព័ន្ធមួយរូប សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌស្នើសុំចុះបញ្ជី។

សម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលស្របតាមច្បាប់កម្ពុជា ។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលបរទេសមិនអាចធ្វើជាប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានឡើយ។

**មាត្រា ២២.-** ការកំណត់ថ្ងៃអាករចុះបញ្ជី

ថ្ងៃអាករចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២៣.-** សំណុំលិខិតសុំចុះបញ្ជីសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដូចខាងក្រោម :

- ពាក្យសុំចុះបញ្ជីដោយប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ(០២)ច្បាប់
- សេចក្តីសម្រេចចុះបញ្ជីរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលជាសមាជិកសម្ព័ន្ធ មួយ(០១)ច្បាប់
- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សម្ព័ន្ធសមាគម ឬរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់ មួយ(០១)ច្បាប់

-លក្ខន្តិកៈរួម ចុះហត្ថលេខាដោយប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ(០២)ច្បាប់

-ប្រវត្តិរូបសង្ខេបរបស់ប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ(០២)ច្បាប់ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤ គុណនឹង៦

-បង្កាន់ដៃថ្លៃអាករចុះបញ្ជីរបស់សម្ព័ន្ធសមាគម ឬរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ(០១)ច្បាប់

ប្រធានសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវធានាថានឹងប្រគល់លិខិតប្រកាសគណនីធនាគាររបស់សម្ព័ន្ធសមាគម ឬរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានផ្ញើនៅធនាគារណាមួយ ទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជាមួយ (០១)ច្បាប់ រយៈពេលយ៉ាងយូរសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលលិខិតសម្រេចចុះបញ្ជី។ ក្នុងករណី មិនបានផ្តល់តាមកាលកំណត់ខាងលើនេះ ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះសម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះចេញពីបញ្ជីវិញ។

**មាត្រា ២៤.**-ពេលវេលាកំណើតនៃនីតិបុគ្គល

សម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គលមិនយកចំណេញ ឬនឹងក្លាយជានីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជីរួចជាស្ថាពរ។

**មាត្រា ២៥.**-ការប្រើឈ្មោះ និងសញ្ញាសម្គាល់របស់សម្ព័ន្ធសមាគម ឬរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានធ្វើសម្ព័ន្ធភាព ត្រូវប្រើឈ្មោះថាសម្ព័ន្ធនៅផ្នែកខាងមុខ និងត្រូវអនុវត្តតាមមាត្រា១១នៃច្បាប់នេះ។

**មាត្រា ២៦.**-បទប្បញ្ញត្តិរបស់សម្ព័ន្ធសមាគម ឬរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សម្ព័ន្ធសមាគម ឬសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលស្របច្បាប់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាដែលមានចែងក្នុងច្បាប់នេះ ដូចសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែរ។

**មាត្រា ២៧.**-កិច្ចសហការរវាងសមាគមជាមួយអង្គការមិនមែនរដ្ឋាភិបាល

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលស្របច្បាប់ អាចធ្វើកិច្ចសហការជាមួយគ្នាបានដើម្បីអនុវត្តគម្រោងណាមួយស្របច្បាប់ តាមសេចក្តីសម្រេចរបស់សមាគម ឬរបស់អង្គការមិនមែន

រដ្ឋាភិបាល។ ក្នុងករណី កិច្ចសហការនោះ មានរយៈពេលចាប់ពីមួយ(០១)ឆ្នាំឡើងទៅ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវ :

- កិច្ចព្រមព្រៀង ឬឯកសារសមមូល ឬល័ក្ខខ័ណ្ឌនានានៃកិច្ចសហការ
- ចំនួន និងឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួម។

## ជំពូកទី ៤

## ការចុះអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

**មាត្រា ២៨.-** សមត្ថកិច្ចចុះអនុស្សរណៈ

ការចុះអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ជាសមត្ថកិច្ចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ២៩.-** ទីស្នាក់ការតំណាង

អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវមានទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣០.-** សំណុំលិខិតសុំចុះអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

អង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងជំនួយនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយភ្ជាប់មកជាមួយនូវសំណុំលិខិត ដូចខាងក្រោម :

- លិខិតរបស់ប្រធានអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស សុំបើកទីស្នាក់ការតំណាងដោយបញ្ជាក់ពីគោលបំណងនៃការបើកទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមួយ(០១)ច្បាប់
- លិខិតរបស់ប្រធានអង្គការមិនមែនរដ្ឋាភិបាលនៅបរទេស ដោយមានភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបរបស់បុគ្គលដែលស្នើតែងតាំងជាតំណាង របស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជាមួយ(០១)ច្បាប់
- ច្បាប់អនុញ្ញាតឱ្យដំណើរការអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយអាជ្ញាធរទទួលខុសត្រូវនៃប្រទេសដើម ដែលជាទីស្នាក់ការអចិន្ត្រៃយ៍របស់អង្គការមិនមែនរដ្ឋាភិបាលបរទេស នោះមួយ(០១)ច្បាប់
- លិខិតគាំទ្រគម្រោងជំនួយនានារបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមួយ(០១)ច្បាប់

-លិខិតប្រកាសគម្រោងថវិកាសម្រាប់អនុវត្តគម្រោងជំនួយនានារបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសយ៉ាងតិចក្នុងរយៈពេលមួយ(០១)ឆ្នាំ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេសមួយ(០១)ច្បាប់

-បញ្ជីឈ្មោះបុគ្គលិកបរទេស និងបុគ្គលិកខ្មែរ ដែលត្រូវបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាមួយ(០១)ច្បាប់

ប្រធានអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវធានាថានឹងប្រគល់លិខិតប្រកាសគណនីធនាគាររបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានផ្ញើនៅធនាគារណាមួយទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជាមួយ(០១)ច្បាប់ រយៈពេលយ៉ាងយូរសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានចុះអនុស្សរណៈ។ ក្នុងករណី មិនបានផ្តល់តាមកាលកំណត់ខាងលើនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវលុបអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសនោះចេញវិញ។

**មាត្រា ៣១.-** បង្កាន់ដៃទទួលពាក្យសុំចុះអនុស្សរណៈ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំចុះអនុស្សរណៈមួយ(០១)ច្បាប់ដល់អង្គការមិនមែនរដ្ឋាភិបាលបរទេសណា ដែលបានបំពេញសំណុំលិខិតគ្រប់គ្រាន់តាមការកំណត់ដូចមានចែងក្នុងមាត្រា៣០នៃច្បាប់នេះ។

**មាត្រា ៣២.-** ការពិនិត្យខ្លឹមសារសំណុំលិខិត និងការឆ្លើយតប

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃនៃថ្ងៃធ្វើការ។

**មាត្រា ៣៣.-** ការចុះកិច្ចព្រមព្រៀងលើគម្រោងជំនួយនានាជាមួយក្រសួង ស្ថាប័នជាដៃគូ

អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើការពិភាក្សាឯកភាពជាមួយក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដែលជាដៃគូលើគម្រោងជំនួយនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងចំណុចទីបួន(០៤)មាត្រា៣០នៃច្បាប់នេះ។ ក្នុងករណី ក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលណាមួយសម្រេចមិនគាំទ្រលើគម្រោងជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ក្រសួង ឬស្ថាប័ននោះ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការបដិសេធ ដោយចម្លងមួយ(០១)ច្បាប់ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ៣៤.-** ការរៀបចំ និងការចុះអនុស្សរណៈ

បន្ទាប់ពីសម្រេចយល់ព្រមលើការចុះអនុស្សរណៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងសម្រាប់ចុះហត្ថលេខាលើអនុស្សរណៈ ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ហើយត្រូវចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយតំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដើម្បីអនុវត្តគម្រោងជំនួយនានារបស់ខ្លួន ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវប្រកាសកិច្ចព្រមព្រៀងលើគម្រោងជំនួយរបស់ខ្លួននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៣៥.-** ពេលវេលាកំណើតនៃនីតិបុគ្គល

អង្គការមិនមែនរដ្ឋាភិបាលបរទេសនឹងក្លាយជានីតិបុគ្គលបរទេស ចាប់ពីថ្ងៃដែលក្រសួងការ-បរទេស និងសហប្រតិបត្តិការអន្តរជាតិបានចុះអនុស្សរណៈរួចជាស្ថាពរ។

នៅក្នុងច្បាប់នេះ អង្គការមិនមែនរដ្ឋាភិបាលបរទេស នឹងទទួលបានបុគ្គលភាពគតិយុត្តិជានីតិបុគ្គលបរទេសលុះត្រាតែអង្គការមិនមែនរដ្ឋាភិបាលបរទេសនោះមានទីស្នាក់ការកណ្ដាលនៅបរទេស និងទទួលស្គាល់ដោយច្បាប់នៃប្រទេសនោះ។

**មាត្រា ៣៦.-** កិច្ចសហការរវាងអង្គការមិនមែនរដ្ឋាភិបាលបរទេសជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ

អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវសហការជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាដៃគូនៅពេលរៀបចំគម្រោងផែនការ ត្រួតពិនិត្យ និងធ្វើការបូកសរុប វាយតម្លៃលទ្ធផលសកម្មភាពដែលបានអនុវត្តរួចហើយ។

ក្នុងករណីមានគម្រោងជំនួយនានានៅរាជធានីភ្នំពេញ ឬនៅបណ្ដាខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដែលជាដៃគូ។

**មាត្រា ៣៧.-** សុពលភាពដំបូងនៃអនុស្សរណៈ និងការសុំបន្តសុពលភាពអនុស្សរណៈ

អនុស្សរណៈនៃការយោគយល់គ្នាមានសុពលភាពដំបូងរយៈពេលយ៉ាងតិច មួយ(០១)ឆ្នាំ ឬច្រើនបំផុតបី(០៣)ឆ្នាំ ទៅតាមគម្រោងជំនួយនានារបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ហើយអាចបន្តសុពលភាពនៃអនុស្សរណៈរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបរទេស តាមលិខិតស្នើសុំរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស។

អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវដាក់លិខិតស្នើសុំបន្តសុពលភាពអនុស្សរណៈឱ្យបានកៅសិប(៩០)ថ្ងៃមុនថ្ងៃផុតសុពលភាពនៃអនុស្សរណៈ។ ក្នុងករណី អង្គការមិនមែនរដ្ឋាភិបាលបរទេស

ណាពុំបានដាក់លិខិតស្នើសុំបន្តសុពលភាពនៃអនុស្សរណៈតាមពេលកំណត់ទេ អង្គការមិនមែនរដ្ឋាភិបាលបរទេសនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយបញ្ជាក់ពីមូលហេតុនៃការយឺតយ៉ាវនេះឱ្យបានសាមសិប(៣០)ថ្ងៃ មុនថ្ងៃផុតសុពលភាពនៃអនុស្សរណៈ។

## ជំពូកទី ៥

## ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ៣៨.-** ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានដូចខាងក្រោម :

-ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក

-ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

-អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬពីនីតិបុគ្គល

-ចំណូលផ្សេងៗដែលបានមកពីសកម្មភាពស្របច្បាប់។

**មាត្រា ៣៩.-** ធនធាន ទ្រព្យសម្បត្តិ និងថវិកាអនុវត្តគម្រោងជំនួយនានារបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

ធនធាននិងទ្រព្យសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសបានមកពីប្រភពស្របច្បាប់។

អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវមានថវិកាគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងជំនួយនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយធានាថាប្រាក់ចំណាយបុព្វហេតុរដ្ឋបាលរួមមាន បៀវត្សរបស់បុគ្គលិក សម្ភារៈការិយាល័យ និងការចំណាយសម្រាប់ដំណើរការការងារក្នុងការិយាល័យ មិនឱ្យលើសពី២៥ភាគរយនៃថវិកាសរុប។

## ជំពូកទី ៦

## សិទ្ធិ និងផលប្រយោជន៍របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ៤០.-** សិទ្ធិជានីតិបុគ្គលរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលស្របច្បាប់ មានសិទ្ធិ :

-ទទួលវិភាគទានហិរញ្ញវត្ថុ ឬអំណោយជាទេយ្យទាន ពីប្រភពស្របច្បាប់

-បើកគណនីធនាគារក្នុងនាមសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនៅធនាគារណាមួយដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា

-ជ្រើសរើសសមាជិក បុគ្គលិក និងកម្មករ

-ជួលដី ឬអគារសម្រាប់អនុវត្តគម្រោងជំនួយនានា

-ចុះកិច្ចសន្យាក្នុងការអនុវត្តគម្រោងជំនួយនានារបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល សំដៅបម្រើផលប្រយោជន៍សាធារណៈ

-ផ្សព្វផ្សាយព័ត៌មាន ឬសកម្មភាពតាមមធ្យោបាយស្របច្បាប់នានា

-ធ្វើជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យតាមច្បាប់ជាធរមាន។

**មាត្រា ៤១.-** ការជ្រើសរើសបុគ្គលិក ឬកម្មកររបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវជ្រើសរើសបុគ្គលិក ឬកម្មករខ្មែរឱ្យបានច្រើនជាអតិបរមា។ ការជ្រើសរើសនេះ ត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយចំនួនបុគ្គលិក ឬកម្មករ ត្រូវសមស្របទៅនឹងគម្រោងជំនួយ។

**មាត្រា ៤២.-** សិទ្ធិ និងផលប្រយោជន៍របស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ ដែលធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំនាំចូលសម្ភារៈ គ្រឿងបរិក្ខារចាំបាច់ សម្រាប់ប្រើប្រាស់ស្របតាមគម្រោងជំនួយរបស់ខ្លួន ដោយពន្ធ និងអាករលើការនាំចូលជាបន្ទុករបស់រដ្ឋ និងតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៤៣.-** ការបើកទីស្នាក់ការសាខា ឬការធ្វើសកម្មភាពរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ អាចបើកទីស្នាក់ការសាខា ឬធ្វើសកម្មភាពនៅរាជធានី ឬនៅបណ្តាខេត្តក្នុងព្រះរាជាណាចក្រកម្ពុជាបាន។ ក្នុងករណីនេះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសាលារាជធានី ឬសាលាខេត្តពាក់ព័ន្ធ ដោយភ្ជាប់ជាមួយនូវឯកសារថតចម្លងដូចជា សេចក្តីសម្រេចចុះបញ្ជី និងលក្ខន្តិកៈ ឬកិច្ចព្រមព្រៀង គម្រោងជំនួយនានា និងអនុស្សរណៈ។ សាលារាជធានី ឬសាលាខេត្តពាក់ព័ន្ធ ត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញការងាររបស់សាមីសមាគម ឬរបស់សាមីអង្គការមិនមែនរដ្ឋាភិបាល ក្នុងភាពជាដៃគូ។

**មាត្រា ៤៤.-** ការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរ ឬការបញ្ឈប់ ឬការបណ្តេញចេញ ឬការដកហូតជំណែង

ប្រធាន ឬថ្នាក់ដឹកនាំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ អាចប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់ ឬធ្វើវិសោធនកម្មលក្ខន្តិកៈ ឬផ្លាស់ប្តូរទីស្នាក់ការ ឬផ្លាស់ប្តូរ ឬបញ្ឈប់ ឬបណ្តេញចេញ ឬដកហូតដំណែងប្រធាន ឬថ្នាក់ដឹកនាំរបស់ខ្លួនបាន ស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន។ ក្នុងករណីនេះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានកែសម្រួលរួច។

**មាត្រា ៤៥.**-អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិរបស់ទីស្នាក់ការតំណាង បុគ្គលិកបរទេស បុគ្គលិកខ្មែរ និងសមាជិកក្រុមគ្រួសាររបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

ទីស្នាក់ការតំណាង បុគ្គលិកបរទេស និងបុគ្គលិកខ្មែរ រួមទាំងសមាជិកក្រុមគ្រួសាររបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ពុំទទួលបានអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិជាអ្នកការទូត ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៣ ស្តីពីទំនាក់ទំនងការទូតឡើយ លើកលែងតែមានកិច្ចព្រមព្រៀងពិសេស រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

បុគ្គលិកបរទេស និងបុគ្គលិកខ្មែរ របស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ពុំមានអភ័យឯក-សិទ្ធិ រួចផុតបណ្តឹងតាមផ្លូវតុលាការ ទាក់ទងនឹងអំពើទាំងឡាយណា ដែលពាក់ពន្ធ័នឹងការបំពេញមុខងាររបស់ខ្លួន រួមទាំងរឿងក្តីគ្រប់ប្រភេទ។

## ជំពូកទី ៧

## ភាតព្វកិច្ចរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ៤៦.**-របាយការណ៍ប្រចាំឆ្នាំរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ ត្រូវធ្វើរបាយការណ៍ស្តីពីសកម្មភាព និងស្ថានភាពថវិកាប្រចាំឆ្នាំកន្លងមក និងផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ ផ្ញើជូនក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនឱ្យហួសពីដំណាច់ខែកុម្ភៈ លើកលែងតែអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលឆ្នាំសារពើពន្ធរបស់ខ្លួន ត្រូវបញ្ចប់នៅក្រោយដំណាច់ខែកុម្ភៈ។

**មាត្រា ៤៧.**-ការតម្កល់ទុករបាយការណ៍ប្រចាំឆ្នាំរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

របាយការណ៍ប្រចាំឆ្នាំរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវតម្កល់ទុករយៈពេលប្រាំ(០៥)ឆ្នាំ ដើម្បីស្ថាប័នមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

**មាត្រា ៤៨.-** សមត្ថកិច្ចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិមានសិទ្ធិត្រួតពិនិត្យរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឱ្យបានមុនពីរ(០២)សប្តាហ៍ដល់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលនោះ។

## ជំពូកទី ៨
## ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ៤៩.-** ការផ្អាកសកម្មភាព ឬការរំលាយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាព ឬរំលាយបាន តាមការកំណត់ក្នុងលក្ខន្តិកៈរបស់ខ្លួន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងមហាផ្ទៃ ឬទៅស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងករណី សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការសម្រេចឱ្យផ្អាកសកម្មភាព ឬឱ្យរំលាយ ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ។

**មាត្រា ៥០.-** ការផ្អាកសកម្មភាព ឬការបញ្ចប់សុពលភាពអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

អង្គការមិនមែនរដ្ឋាភិបាលបរទេសអាចស្នើសុំផ្អាកសកម្មភាព ឬសុំបញ្ចប់សុពលភាពអនុស្សរណៈបាន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចម្លងជូនស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័។

ក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលសាលក្រម ឬសាលដីការបស់តុលាការសម្រេចឱ្យផ្អាកសកម្មភាព ឬឱ្យបញ្ចប់សុពលភាពអនុស្សរណៈ ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ។

**មាត្រា ៥១.-** ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ ឬបានបញ្ចប់សុពលភាពអនុស្សរណៈ ដោយខ្លួនឯង

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានរំលាយដោយខ្លួនឯង ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៤៩ នៃច្បាប់នេះ ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលត្រូវបានអនុញ្ញាតឱ្យបញ្ចប់សុពលភាពអនុស្សរណៈ ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៥០ នៃច្បាប់នេះ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមលក្ខន្តិកៈ ឬតាមអនុស្សរណៈ ឬតាមសេចក្តីសម្រេចរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលនោះ។

**មាត្រា ៥២.-** ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ ឬបានបញ្ចប់សុពលភាពអនុស្សរណៈ តាមសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានរំលាយ ឬបញ្ចប់សុពលភាពអនុស្សរណៈតាមសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ ដែលបង្គាប់ឱ្យរំលាយ ឬឱ្យបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

## ជំពូកទី ៩
## នីតិវិធីដោះស្រាយបទល្មើស និងទោសប្បញ្ញត្តិ

**មាត្រា ៥៣.-** ការប្រព្រឹត្តល្មើស

ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់មិនបានអនុវត្តតាមមាត្រា៤៦ នៃច្បាប់នេះ ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមិនអនុវត្តតាមការព្រមាន ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្តោះអាសន្នក្នុងរយៈពេលពីមួយ(០១)ខែ ទៅបី(០៣)ខែ។

អង្គការមិនមែនរដ្ឋាភិបាលបរទេសមិនអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាព និងបញ្ចប់សុពលភាពអនុស្សរណៈ។

**មាត្រា ៥៤.-** ការប្រព្រឹត្តល្មើសនឹងលក្ខន្តិកៈ ឬអនុស្សរណៈ

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលស្របច្បាប់ណា ដែលបានអនុវត្តមិនត្រឹមត្រូវតាមលក្ខន្តិកៈ ឬអនុស្សរណៈ ក្រសួងមហាផ្ទៃ ឬស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរទៅសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ។

ក្នុងករណីមិនរាងចាល ឬបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ប៉ះពាល់ដល់រដ្ឋធម្មនុញ្ញ ឬច្បាប់នានា

នៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៥.-** ការចុះបញ្ជីឡើងវិញរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានតម្កល់សំណុំលិខិតនៅតាមស្ថាប័នរដ្ឋនានា ត្រូវរៀបចំសំណុំលិខិតសុំចុះបញ្ជីសាជាថ្មីឡើងវិញ ស្របតាមការកំណត់ដូចមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃច្បាប់នេះ រយៈពេលយ៉ាងយូរបីរយហុកសិបប្រាំ(៣៦៥)ថ្ងៃ។ បើហួសរយៈពេលដូចបានកំណត់ខាងលើនេះ ត្រូវចាត់ទុកជាមោឃៈ។

**មាត្រា ៥៦.-** ការបន្តសុពលភាពអនុវត្តនៃអនុស្សរណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស

បន្ទាប់ពីច្បាប់នេះចូលជាធរមាន អង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ នៅមានសុពលភាពអនុវត្តបន្ត។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-** និរាករណ៍បទប្បញ្ញត្តិ ដែលផ្ទុយនឹងច្បាប់នេះ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥៨.-** ការចូលជាធរមាននៃច្បាប់

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។